ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០១
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩
សាលដីកា
លេខ ៧៦ VIII
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម (របាយការណ៍)

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ១៥៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សុភី ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រV “សស” ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

- **ជនជាប់ចោទ៖**

១.ឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលចាប់ខ្លួនស្នាក់នៅ

Scanned with CamScanner

[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ជានីតិជន ។ (អ្នកប្ដឹងសាទុក្ខ)

.ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាលេខ ៥២៣៨ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-មានលោក [redacted] សុនី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ។

២.ឈ្មោះ [redacted] ឆាវ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

៣.ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៤.ឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតភូមិ [redacted] ខេត្តតាកែវ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] គ្មានកូន ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារតារប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] សុផល ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរនិស្សិត ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ នៅចំណុចផ្ទះលេខ២៣០ ផ្លូវលេខ៩៣ ក្រុមទី១៧ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានករណី លួចមានស្ថានទម្ងន់ទោស ខណៈពេលជនរងគ្រោះឈ្មោះ [redacted] សុផល បានជិះម៉ូតូម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ ពាក់ស្លាកលេខ ១CR-១៩៦៣ ទៅយកមិត្តភក្តិនៅកន្លែងកើតហេតុខាងលើ ពេលអង្គុយឈប់ចាំមិត្តភក្តិ ស្រាប់តែមានជនត្រូវចោទមកឈប់ទន្ទឹមនឹងម៉ូតូជនរងគ្រោះ រួចលូកដកសោរម៉ូតូពីជនរងគ្រោះ ហើយជិះម៉ូតូជនរងគ្រោះគេចខ្លួនបាត់តែម្ដង។ លុះដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ កម្លាំងនៃអធិការដ្ឋាននគរបាលខណ្ឌចំការមន បានធ្វើការបង្ក្រាបជាក់ស្ដែង និងឃាត់ខ្លួនបានជនត្រូវចោទឈ្មោះ [redacted] សំណាង នៅចំណុចសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ពីបទ លួចមានស្ថាន



Scanned with CamScanner

ទម្ងន់ទោស ក្រោយពីធ្វើការសាកសួរជនត្រូវចោទបានសារភាពថា នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួននិងបក្ខពួករួមមានឈ្មោះ ធារ៉ា, ឈ្មោះ [redacted] ពិទូ និងឈ្មោះ [redacted] សុផល ពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូជនរងគ្រោះឈ្មោះ [redacted] សុផល ប្រាកដមែន។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឡ" ក្រ៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១- ផ្តន្ទាទោសជនជាប់ចោទ ៖

ក. ឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ

ខ. ឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ

គ. ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ

ឃ. ឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៧ (ប្រាំពីរ) ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២- ទុកសិទ្ធិឲ្យដើមបណ្តឹងឈ្មោះ [redacted] សុផល ប្តឹងទាមទារសំណងរដ្ឋប្បវេណី នៅពេលក្រោយ ។

- សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ [redacted] សំណាង និងឈ្មោះ [redacted] ពិទូ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុផល, ឈ្មោះ [redacted] ធារ៉ា ដើមបណ្តឹងឈ្មោះ [redacted] សុផល ។

ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ធា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឡ" ក្រ៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤១៤ "ឡ" ក្រ៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឡ" ក្រ៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ធា ។



Scanned with CamScanner

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១០៧ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់លោក [redacted] សីហា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឡ" ក្រ៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៨១ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ធា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤១៤ "ឡ" ក្រ៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ ៥៤ ក្រV "សស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១០៧ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់មេធាវី [redacted] សីហា ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទ [redacted] ពិទូ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៨១ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ ឡ "ក្រ៣" ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូលដដែល។

៤-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤១៤ "ឡ" ក្រ៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូលដដែល។

៥-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ ចាន់ ពិទូ និងជនជាប់ចោទឈ្មោះ [redacted] ធារ៉ា និងកំបាំងមុខដើមបណ្តឹង រដ្ឋប្បវេណីឈ្មោះ [redacted] សុផល ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ១៥៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ របស់លោក [redacted] សុភី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV "សស" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖ ជនជាប់ចោទឈ្មោះ [redacted] ពិទូ ក៏ដូចជាជនជាប់ឈ្មោះ [redacted] ធារ៉ា បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ក៏ប៉ុន្តែមានចម្លើយជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយថាឈ្មោះ [redacted] ធារ៉ា និងឈ្មោះ [redacted] ពិទូ ជាអ្នកជិះម៉ូតូបិទគូទក្នុងករណី



Scanned with CamScanner

លួចមានហិង្សានេះ ហើយក៏មានចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ផាភ៉ា និងឈ្មោះ [redacted] ពិទូ ថាពួកខ្លួនមានសំណុំរឿងជាច្រើនជាប់ពាក់ព័ន្ធបទល្មើសប្លន់ប្រដាប់អាវុធ ដែលមានសាលក្រមព្រហ្មទណ្ឌមួយចំនួនបានផ្ដន្ទាទោសលើជនជាប់ចោទទាំង ០៤នាក់ នេះមានលក្ខណៈស៊ីសង្វាក់ដែលបញ្ជាក់បានថាឈ្មោះ [redacted] ពិទូ ពិតជាបានចូលរួមប្រព្រឹត្ត ។

តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជំរះសម្រេច៖

តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV "សស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

+ជនជាប់ចោទឈ្មោះ [redacted] ពិទូ ឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្ញុំបាទពុំបានដឹងរឿងអ្វីទេ ពេលនោះខ្ញុំកំពុងនៅផ្ទះមើលកូនហើយក៏ពុំដែលស្គាល់គេទាំងនោះដែរ ។ ខ្ញុំធ្លាប់ធ្វើជាប៉ូលីស និងជាអ្នកបើកឡានឱ្យឯកឧត្ដម [redacted] អស់រយៈពេល ០៤ទៅ ០៥ឆ្នាំ ប៉ុន្តែខ្ញុំពុំមានអាវុធកាន់នោះទេ ហើយខ្ញុំមិនដែលស្គាល់ឈ្មោះ ផាភ៉ា នោះឡើយ ។ ខ្ញុំមានសំណុំរឿងចំនួន ០៤សំណុំរឿង នៅសាលាដំបូងរាជធានីភ្នំពេញ ហើយពេលនេះមានរឿងខ្លះចូលជាស្ថាពរហើយ ។

សំណូមពរ សូមតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្ញុំបាទផង ។

+លោក [redacted] សុភី ជាមេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ កន្លងមកកូនក្តីខ្ញុំជាប់ចោទចំនួន ០៤សំណុំរឿង ឈ្មោះ តួ ដែលជាគូរកនរបស់ឈ្មោះ [redacted] សំណាង ចំពោះភិនភាគរបស់ឈ្មោះ តួ មានលក្ខណៈខុសគ្នាដាច់ស្រឡះពីកូនក្តីខ្ញុំបាទ ។ ខ្ញុំបានស្នើសុំទៅឯកឧត្ដមប្រធានក្រុមប្រឹក្សាសាលាឧទ្ធរណ៍ ឱ្យកោះហៅជនជាប់ចោទដែលជាប់ពាក់ព័ន្ធ និងសាក្សីមួយចំនួន នៅពេលសួរតទល់ឈ្មោះ [redacted] សំណាង បានអះអាងថារូបគេពុំដែលស្គាល់កូនក្តីខ្ញុំទេ ហើយកូនក្តីខ្ញុំក៏ពុំដែលស្គាល់ឈ្មោះ [redacted] សំណាង ដូចគ្នា កូនក្តីខ្ញុំនៅតែរក្សាការបដិសេធនៅគ្រប់ដំណាក់កាលតាំងពីសាលាដំបូងរហូតមកដល់ពេលនេះ ។ ចៅក្រមនៅសាលាឧទ្ធរណ៍បានស្នើទៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញធ្វើការបំពេញកិច្ចឱ្យឈ្មោះ [redacted] សំណាង ទៅចង្អុលបង្ហាញផ្ទះរបស់ឈ្មោះ តួ ឃើញថា ផ្ទះនោះមិនមែន ជាផ្ទះរបស់កូនក្តីខ្ញុំទេ ។ ឃើញថា នៅមានការខ្វះចន្លោះក្នុងនីតិវិធី ដែលពុំមានអ្វីអាចបញ្ជាក់ថាកូនក្តីខ្ញុំប្រព្រឹត្តបទល្មើសនោះទេ ហើយឈ្មោះ [redacted] សំណាង ដែលបានឆ្លើយអំពីអត្តសញ្ញាណរបស់គូរកននោះ ក៏មិនច្បាស់លាស់ដែរ កូនក្តីខ្ញុំត្រូវបានសមត្ថកិច្ចឃុំខ្លួនរយៈពេល ០៤ឆ្នាំ ហើយ ព្រោះតែការយល់ច្រឡំរវាងឈ្មោះ តួ និង ចាន់ ពិទូ តែប៉ុណ្ណោះ ។

សំណូមពរ សូមតុលាការមេត្តាបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ជំនុំជម្រះសាជាថ្មី ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។



Scanned with CamScanner

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៥៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សុភី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា រឿងក្តីនេះ តុលាការអង្គហេតុបានប្រកាសទោសលើជនជាប់ចោទជាច្រើនរូប ហើយជនជាប់ចោទឈ្មោះ [redacted] ពិទូ និងឈ្មោះ [redacted] ធារ៉ា ជាបុគ្គលប្តឹងឧទ្ធរណ៍ ឯការបណ្តឹងសាទុក្ខ គឺធ្វើឡើងតែជនជាប់ចោទឈ្មោះ [redacted] ពិទូ ដែលប្តឹងប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV “សស” ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលនោះ តាមបញ្ញត្តិមាត្រា ៤១៩, ៤៣៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខនេះមានអានុភាពឱ្យតុលាការកំពូលពិចារណាត្រឹមផលប្រយោជន៍របស់បុគ្គលប្តឹងសាទុក្ខជនជាប់ចោទឈ្មោះ [redacted] ពិទូ ប៉ុណ្ណោះ។

៣-យល់ឃើញថា ក្នុងដំណាក់កាលកិច្ចពិភាក្សាដេញដោលជាសាធារណៈនៅតុលាការកំពូល មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ បានបញ្ចូលឯកសារថ្មីមួយចំនួន ដូចជា កំណត់ហេតុស្តាប់ចម្លើយជនជាប់ចោទជាបក្ខពួកឈ្មោះ [redacted] សំណាង, លទ្ធផលនៃការស៊ើបសួរលេខ ៤១១៧រប/១៩ របស់សាលាដំបូងរាជធានីភ្នំពេញ, សាលដីកាព្រហ្មទណ្ឌលេខ ២៥ ក្រ VI “បស” ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ និងសាលដីកាព្រហ្មទណ្ឌលេខ ១៩៦ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់តុលាការកំពូល ដែលខ្លឹមសារនៃឯកសារទាំងនេះ ជាភស្តុតាងដោះបន្ទុក និងអាចមានឥទ្ធិពលដល់អត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ពិទូ ក្នុងអង្គហេតុនៃរឿងក្តីនេះ ហើយឯកសារនេះ មិនទាន់បានបញ្ចូលក្នុងសំណុំរឿងដើម្បីធ្វើការវាយតម្លៃដោយតុលាការអង្គហេតុនៅឡើយ។ ដូច្នេះ តាមមាត្រា ៣២១, មាត្រា៤៣៤ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការកំពូលបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ដើម្បីពិចារណាសម្រេច ដោយវាយតម្លៃនៃភស្តុតាងជាថ្មី រួមនឹងភស្តុតាងផ្សេងៗទៀត។

៤-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថារឿងក្តីនេះមានភស្តុតាងគ្រប់គ្រាន់អស់ហើយ និងសុំតម្កល់សាលដីកាសភាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍។ ករណីនេះ តុលាការកំពូលបានពិចារណាដូចមានក្នុងសំអាងហេតុខាងលើ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV “សស” ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមគតិច្បាប់ទេ ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួលបណ្តឹងសាទុក្ខលេខ ១៥៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សុភី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិទូ ។



Scanned with CamScanner

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV "សស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ពិទូ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃ២៥ ខែមីនា ឆ្នាំ២០២០

Scanned with CamScanner